

# ព្រះគុណម្ដាយ



អ្នកម្ដាយចាយគុណពន់ប្រមាណ
កូនឈឺកូនឃ្លានមានអ្នកថ្លៃ
បីបមថ្នាក់ថ្នមលោមប្រណី
ឱ្យកូនផុតភ័យបានក្ដីសុខ។

អាយុកូនកើនចម្រើនកាយ
ប្រាជ្ញប្រាណពណ្ណរាយសាយទំនុក
ព្រោះមានម៉ាក់ប៉ាជាប្រមុខ
ចង្អុលផ្លូវទុកដោយដើមដាន។

កាលកូននៅក្មេងឆ្វេងសេចក្ដី
ពេលខ្លះធ្វើអ្វីតាមចិត្តស្មាន
មាត់ធំមាត់តូចខូចបំពាន
ទុកការទូន្មានជាសត្រូវ។

អ្នកម្ដាយចិត្តធ្ងន់ពន់ក្ដីទុក្ខ
ទោះកូនរំអុកមុខក្រញូវ
ឬករឹងក្រញាសប្រាសខុសផ្លូវ
អ្នកម្ដាយចាំនៅប្រដៅបុត្រ។

យកក្ដីស្រលាញ់ចិត្តករុណា
ទាញចិន្ដាកូនពីសមុទ្រ
នៃក្ដីល្ងង់ខ្លៅខ្មៅស្មុគទ្រុឌ
ឱ្យកូនឆ្លងផុតអវិជ្ជា។



រំឭកដល់គុណអ្នកមេថ្លៃ
កូនឱនសិរសីដៃវន្ទា
សុំខមាទោសដល់វេលា
ដែលកូនពុំជាពុំគប្បី។



កូនចង់ឱ្យម៉ាក់បានដឹងច្បាស់
មានមនុស្សច្រើនណាស់លើលោកិយ
មិនមែនម្ដាយណាក៏ប្រពៃ
លះបង់អ្វីៗដើម្បីកូន។

កូនសូមជូនពរបវរជាក់
សូមម៉ាក់កុំមានភ័ក្ត្រស្រពោន
សូមព្រះគុណម្ដាយចាយជាក្សួន
ចម្លងថែវជូនម៉ាក់បានសុខ។

**ដោយក្ដីស្រលាញ់អំពីកូនស្រី**

**ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី**